# ការផ្ដល់អោយកុមារនូវ (ការសិក្សាដែលសប្បាយរីករាយ) និង (សមត្ថភាពនៃការគិត)។



បច្ចុប្បន្ននេះ ក្នុងខណៈពេលដែលសេដ្ឋកិច្ចប្រទេសកម្ពុជាកំពុងមានការលូតលាស់ ចំនួនប្រជាជនដែលមានប្រាក់ចំណូលកម្រិតមធ្យមមានការកើនឡើង រីឯតម្រូវការសម្រាប់វិស័យអប់រំក៏មានការកើនឡើងដែរ។ ក៏ប៉ុន្តែបើយើងក្រឡេកមើលស្ថានភាពជាក់ស្ដែងនៅក្នុងវិស័យអប់រំវិញ យើងសង្កេតឃើញថាវិធីសាស្ត្រនៃការបង្រៀនរបស់គ្រូដល់សិស្សនៅមានកម្រិត។ ដូច្នេះហើយ JICA កំពុងព្យាយាមបង្កើនសមត្ថភាពនៃការគិតដល់កុមារ និងផ្ដល់ឲ្យកុមារទាំងអស់នូវសិក្សាដែលសប្បាយរីករាយតាមរយៈការបង្កើតនូវសៀវភៅគ្រូបង្រៀនដែលណែនាំអំពីវិធីសាស្ត្រនៃការបង្រៀនសម្រាប់គ្រូកម្រិតអនុវិទ្យាល័យផ្ដោតលើមុខវិជ្ជា វិទ្យាសាស្ត្រ និងគណិតវិទ្យាក្នុងគោលបំណងដើម្បីឲ្យពួកគាត់ទទួលបានចំណេះដឹងបន្ថែមអំពីវិធីសាស្ត្របង្រៀន និងយកចំណេះដឹងទាំងនេះទៅចែករំលែកបន្តដល់គ្រូដទៃទៀត។

សរុបសេចក្ដីមក ប្រសិនបើវិស័យអប់រំមានការអភិវឌ្ឍន៍ នាំអោយសង្គមមានការអភិវឌ្ឍន៍ហើយប្រទេសជាតិក៏កាន់តែមានការអភិវឌ្ឍន៍។

JICA